# វិសោធនកម្មមាត្រា ៦៣នៃបទប្បញ្ញត្តិ ស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធី ព្រហ្មទណ្ឌ២០០៦

# ព្រះរាជក្រម

នស/រកម/០៦០៦/០១៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៦៣នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានពិនិត្យ និងផ្តល់យោបល់យល់ស្របលើទម្រង់ និងគតិច្បាប់ព្រមទាំងលើខ្លឹមសារនៃអត្ថបទច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្ត នៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល

**មាត្រាមួយ.-**

ត្រូវបានកែប្រែមាត្រា ៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលដូចខាងក្រោម :

**មាត្រា ៦៣ ថ្មី .- ការបរិហារកេរ្តិ៍ និងការជេរប្រមាថ**

១-គ្រប់ការពោលអះអាង ឬ គ្រប់ការទម្លាក់កំហុសដោយអសុទ្ធចិត្ត នូវអំពើជាកំណត់ណាមួយ ដែលប៉ះពាល់ដល់កិត្តិយស ឬ កេរ្តិ៍ឈ្មោះរបស់បុគ្គលឯកជន អំពើដែលនាំឱ្យកើតសៅហ្មងដល់ជននោះ គឺចាត់ជាការបរិហារកេរ្តិ៍ ។ ការផ្សាយដោយផ្ទាល់ ឬ ផ្សាយបន្តនូវការពោលអះអាងនោះ ឬ ការទម្លាក់កំហុសនោះ ត្រូវមានទោស ទោះបីសំដៅទៅលើជនណាមួយ ដោយមិនចេញឈ្មោះជាក់លាក់ក៏ដោយ ប៉ុន្តែភិនភាគបានបញ្ជាក់ច្បាស់តាមន័យក្នុងសុន្ទរកថា តាមសម្រែក តាមការគំរាមកំហែង តាមការសរសេរ ឬ តាមការបោះពុម្ពតាមផ្ទាំងបដា ឬ ប័ណ្ណប្រកាស តាមការផ្សាយសោតទស្សន៍ដែលជាប់ចោទ ។ គ្រប់ការពោលអះអាង ឬ ការទម្លាក់កំហុស ដែលអ្នកនិពន្ធ អ្នកសារព័ត៌មាន អ្នកទទួលខុសត្រូវខាងការផ្សាយ អ្នកទទួលខុសត្រូវខាងការបោះពុម្ពផ្សាយ នាយកកម្មវិធី ដែលដឹងថាមិនពិតហើយ នៅតែផ្សាយ បោះពុម្ពផ្សាយ សរសេរ ឬ ផ្សព្វផ្សាយក្នុងបំណងបំផ្លាញបុគ្គលសាធារណៈណាមួយ អំពើដែលនាំឱ្យកើតសៅហ្មងដល់ជននោះ គឺជាការបរិហារកេរ្តិ៍ ។

២-គ្រប់ពាក្យជេរប្រមាថធ្ងន់ៗ ពាក្យមើលងាយ ឬ ពាក្យជេរដែលគ្មានការទម្លាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ ។

៣-ការបរិហារកេរ្តិ៍ ឬ ការជេរប្រមាថប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា ៥៩ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀល (មួយលានរៀល) ទៅ ១០.០០០.០០០ រៀល (ដប់លានរៀល) ។

៤-ម្យ៉ាងទៀត ក្នុងករណីដែលមានការផ្តន្ទាទោសអំពីអំពើណាមួយដែលមានចែងក្នុងកថាខណ្ឌខាងលើ តុលាការអាចបញ្ជាឱ្យបិទផ្សាយសេចក្តីសម្រេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ ដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារព័ត៌មានមួយ ឬ ច្រើន ដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ រហូតដល់កម្រិតច្រើនបំផុត ១០.០០០.០០០ រៀល (ដប់លានរៀល) ។ បណ្តឹងអាជ្ញាដែលទាក់ទងនឹងបទមជ្ឈិមដែលមានចែងក្នុងមាត្រានេះ អាចធ្វើឡើងបានតាមរយៈគ្រប់សមាគម ដែលតាំងឡើងតាមវិធានដែលកំណត់ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដោយដាក់ពាក្យបណ្តឹងជាភាគីរដ្ឋប្បវេណីជូនរដ្ឋអាជ្ញាមានសមត្ថកិច្ច ។

៥-ក្នុងករណីណាក៏ដោយ និយោជក អ្នកបោះពុម្ព ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬ ក្រុមហ៊ុនផ្សព្វផ្សាយ ត្រូវទទួលខុសត្រូវរួមក្នុងការសងជំងឺចិត្តផ្សេងៗ ដែលអាចនឹងត្រូវផ្តល់ឱ្យជនរងគ្រោះម្នាក់ ឬ ច្រើននាក់ ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦

ពាល.០៦០៦.២៩០ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍានា**

លេខ ២៦៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០០៦

**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី**

**ស៊ុន ចិនកេន**